# ទង់ក្រពើ

ទង់មានន័យថា ជាផ្ទាំងសំពត់ ឬចម្រៀកសំពត់ ដែលដេរឱ្យមានសណ្ឋាន និងពណ៌ ឬរូបរាងផ្សេងៗ សម្រាប់ប្រើជាកិត្តិយសក្នុងប្រទេសមួយៗ ឬក៏ប្រើជាគ្រឿងសម្គាល់តាមសណ្តាប់សាសនានីមួយៗ ប្រើជាគ្រឿងបូជាក៏មាន សូម្បីធ្វើដោយក្រដាសក៏ហៅថាទង់ដែរ។[1] ទង់មានច្រើនប្រភេទដូចជាទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ ឬទង់សម្រាប់ការធ្វើសង្គ្រាមជាដើម។ ការប្រើប្រាស់ទង់នៅក្នុងសង្គមខ្មែរមានសារៈសំខាន់ខ្លាំងណាស់ ហើយទំនៀមនេះបានបន្តតាំងពីបុរាណកាលមកម្ល៉េះ ដោយក្នុងនោះមានឧទាហរណ៍ជាច្រើនបង្ហាញនៅលើចំលាក់តាមប្រាង្គប្រាសាទបុរាណខ្មែរនានា។ ប៉ុន្តែអាស្រ័យដោយទង់មានច្រើនប្រភេទ ហើយមានតួនាទីផ្សេងៗគ្នានៅក្នុងសង្គមខ្មែរ នៅក្នុងអត្ថបទនេះនឹងលើកយកមកបង្ហាញតែទង់ក្រពើមួយប៉ុណ្ណោះ ដោយសារជាប្រភេទទង់ដែលប្រជាជនខ្មែរគ្រប់ស្រទាប់វណ្ណៈធ្លាប់ឃើញធ្លាប់ស្គាល់ ប៉ុន្តែប្រហែលជាមិនបានដឹងទូលំទូលាយអំពីដំណើរដើមទងនៃការប្រើប្រាស់ទង់ក្រពើនៅឡើយ។

ទង់ក្រពើ គឺជាទង់ដែលដេរពីកំណាត់ស ដែលមានថ្នាំងចំនួន៦ ទៅ៨ ហើយមានរូបរាងស្រដៀងនឹងសត្វក្រពើ ហើយពេលខ្លះគេហៅទង់ក្រពើថា ទង់អភិធម្ម ប៉ុន្តែក្នុងសម័យបច្ចុប្បន្នថ្នាំងទង់មានការប្រែប្រួលចំនួន(រូបលេខ១-៣)។ កាលណាមានមនុស្សស្លាប់គេតែងយកទង់ក្រពើ១ ឬ២មកចងនៅមុខផ្ទះ ហើយដោយមិនមានពាក់ហ៊ោសប្បាយអឺងកងដូចការលើកទង់ផ្សេងៗនោះទេ។ នៅក្នុងតំបន់ខ្លះ កាលណាមានអ្នកស្លាប់គេលើកទង់ក្រពើតែ១ ឯតំបន់ខ្លះទៀតគេលើកទង់ក្រពើចំនួន២ ប៉ុន្តែទាំងនេះសំដៅលើមនុស្សស្លាប់តែម្នាក់ប៉ុណ្ណោះ។ ការចងទង់ក្រពើចំនួនពីរ មិនមែនមានន័យថាផ្ទះនោះមានមនុស្សស្លាប់ពីរនាក់នោះទេ គឺសំដៅសម្រាប់មនុស្សស្លាប់តែម្នាក់ប៉ុណ្ណោះ (រូបលេខ២)។ ទំនៀមនេះមិនមានខុសទាស់អ្វីនោះទេ គឺអាស្រ័យទៅលើការប្រតិបត្តិរបស់ប្រជាជនក្នុងតំបន់នីមួយៗ។ ជាទូទៅ ក្រោយបូជាសពរួចហើយ គេទម្លាក់ទង់ក្រពើចុះវិញភ្លាម ប៉ុន្តែមានស្រុក

[1] ជួន ណាត ១៩៦៧: ៤០២

អត្ថបទដោយ៖ មាស សុភាព

ខ្ទះ ដូចជានៅបាត់ដំបង គេដោតទង់ក្រពើរហូតដល់ទៅ១០០ថ្ងៃ ឬរហូតដល់ទង់ផុយរលួយក៏សឹងតែមាន។[២]

ការលើកទង់ក្រពើ ឬទង់អភិធម្មនៅមុខផ្ទះ មិនមែនត្រឹមតែបង្ហាញថាផ្ទះនោះមានមនុស្សស្លាប់នោះទេ ប៉ុន្តែគឺជាគំនិតនៃការរៀបចំទុកដាក់សពឱ្យបានល្អត្រឹមត្រូវនៅក្នុងផ្ទះសម្បែង ឬក្នុងកុដិ ដែលក្នុងបំណងប្រដូចទៅនឹងការតម្កល់សាកសព ឬការបញ្ចុះនៅក្នុងព្រះចូឡាមណីចេតិយ នៅឯស្ថានត្រៃត្រឹង្ស។[៣]

ទាក់ទងនឹងទង់ក្រពើនេះ មានតំណាលពីរផ្សេងគ្នា ដោយតំណាលទី១ មានលក្ខណៈជាបែបប្រវត្តិសាស្ត្រផង រឿងព្រេងផង។ ចំណែកតំណាលទី២ គឺភ្ជាប់ទំនាក់ទំនងនឹងព្រះពុទ្ធសាសនាតែម្តង។

**ក. តំណាលទី១**

នៅក្នុងរាជព្រះបាទអង្គច័ន្ទទី២ ដែលជាព្រះមហាក្សត្រនៅក្នុងសម័យឧដុង្គ (សតវត្សទី១៧ ដល់ទី១៩ នៃគ្រិស្តសករាជ) ព្រះអង្គមានបុត្រីមួយអង្គ ព្រះនាម ក្រពុំឈូក។ នៅក្នុងព្រះជន្ម១៦ព្រះវស្សា ព្រះនាងត្រូវបានក្រពើដ៏ធំមួយ ឈ្មោះ អាធន់ ដែលក្លាយខ្លួនមកពីលោកនេនមួយអង្គឈ្មោះ នេនធន់ លេបទាំងរស់។ ក្រោយហេតុការនេះ ព្រះមហាក្សត្រមានក្តីសោកសង្រេងខ្លាំងណាស់ ក៏ឱ្យគេផ្សងកន្ទោងខៀវតាមចាប់ក្រពើអាធន់ឱ្យបាន។ លុះពេលកន្លងទៅបាន៧ថ្ងៃ គេក៏ចាប់ក្រពើអាធន់បាននៅខេត្តក្រចេះ។ ជាអកុសលក្រោយវះពោះក្រពើនោះ ព្រះនាងក្រពុំឈូកបានសុគតបាត់ទៅហើយ ដូច្នេះដោយសេចក្តីស្រលាញ់អាណិតអាសូរបុត្រី ព្រះមហាក្សត្របានឱ្យគេសង់វិហារសសរ១០០ នៅត្រង់កន្លែងដែលព្រះអង្គឱ្យគេវះពោះក្រពើអាធន់នោះ។ នៅមុខព្រះវិហារ ព្រះអង្គឱ្យគេសង់ចេតិយមួយយ៉ាងធំ ហើយឱ្យចាប់ស្ត្រីមានផ្ទៃពោះចំនួន២០នាក់ មកសម្លាប់កាត់ក្បាលដាក់ជាគ្រឹះចេតិយនេះ។ បន្ទាប់មកបានសង់ព្រះរូបព្រះនាងក្រពុំឈូកឈរនៅលើចេតិយ

---

[២] ម៉ៅ សេងយាន ២០០៧: ១៦

[៣] Ibit

តែម្តង។ ចំណែកក្រពើអាជន់ ត្រូវគេពន្ធះស្បែកទាំងអស់ ហើយយកទៅក្តាងនៅមុខចេតិយព្រះនាងក្រពុំឈូកនោះ (រូបលេខ៥)។[៨]

**ខ. តំណាលទី២**

ក្នុងព្រះពុទ្ធកាល សម័យដែលព្រះអង្គគង់ជាធរមាននៅឡើយ មានក្រពើពីរក្បាលញីឈ្មោលបានមកសុំព្រះអង្គបួស ប៉ុន្តែដោយជាសត្វតិរច្ឆាន ព្រះសម្មាសម្ពុទ្ធមិនបានអនុញ្ញាតិឱ្យបួសសំណាក់ក្នុងសាសនាព្រះអង្គឡើយ។ ប៉ុន្តែដោយឧបនិស្ស័យនឹងសាសនារបស់ព្រះពុទ្ធ ក្រពើទាំងពីរបានសំណូមពរថា" ប្រសិនបើខ្ញុំស្លាប់ទៅ សូមព្រះអង្គឱ្យគេយកស្បែកយើងខ្ញុំដោតធ្វើជាទង់ថ្វាយចំពោះព្រះភ័ក្ត្រព្រះអង្គ ទុកជាសក្ការៈបូជាកុំបីកន្ទង់ឡើយ" ដូច្នេះព្រះសម្មាសម្ពុទ្ធក៏ទ្រង់ទទួលតាមសំណូមពរដោយក្តីករុណា (រូបលេខ៦)។ ក្រោយពីក្រពើទាំងពីរស្លាប់ទៅ គេក៏យកស្បែកក្រពើទៅដោតថ្វាយតាមសំណូមពរមែន។ លុះដល់ព្រះសម្មាសម្ពុទ្ធចូលបរិនិព្វានទៅ ស្បែកក្រពើនោះក៏ផុយរលួយអស់ ដូច្នេះគេបានយកសំពត់ស មករចនាធ្វើជារូបរាងក្រពើ ដោតជំនួសឱ្យស្បែកក្រពើដែលផុយរលួយនោះតរៀងមក។[៩]

សរុបមកការដោតទង់ក្រពើនៅផ្ទះរបស់អ្នកស្លាប់គឺជាទំនៀមចាស់ ដែលមានតំណាលផ្សារភ្ជាប់នឹងប្រវត្តិសាស្ត្រផង និងជំនឿក្នុងព្រះពុទ្ធសសនាផង។ ទង់ក្រពើ គឺធ្វើពីកំណាត់សំពត់ ឬក្រដាស ដែលតំណាងឱ្យស្បែកក្រពើ ដែលគេពន្ធះមកចងក្តាងនៅមុនចេតិយព្រះនាងក្រពុំឈូក និងនៅពីមុខព្រះភ័ក្ត្រព្រះសម្មាសម្ពុទ្ធ។ ទង់ក្រពើជាទង់ដែលមានទំនាក់ទំនងជាមួយនឹងសេចក្តីស្លាប់ផង ការបូជាខ្លួននឹងសាសនាផង។ អាស្រ័យហេតុនេះបានជាទង់ដែលមានរូបរាងដូចក្រពើមិនមែនចង់ តែនៅពីមុខផ្ទះអ្នកស្លាប់នោះទេ ប៉ុន្តែក៏ចងនៅក្បែរព្រះរូបព្រះពុទ្ធនៅក្នុងព្រះវិហារព្រះពុទ្ធសាសនានានាផងដែរ។ ប៉ុន្តែពេលខ្លះទង់ក្រពើដែលចងនៅជិតព្រះពុទ្ធរូប ក៏មានពណ៌ដោយឡែកពីពណ៌សផងដែរ។

---

[៨] ញាណ គឿន, ម៉ម ផៃ ២០០២:៩០-៩១

[៩] ញាណ គឿន, ម៉ម ផៃ ២០០២:៨៨-៨៩

# បញ្ជីរូបភាព



រូបភាពទី១ ទង់ក្រពើ ដែលមានធ្នឹង៨

(រូបថត: Entertainment And Knowledge)



រូបភាពទី២ ទង់ក្រពើ ដែលមានធ្នឹង១០ (រូបថត: Khmerload)



រូបភាពទី៣ ទង់ក្រពើ ដែលមានធ្នឹង៤ (រូបថត: Khmerload)

អត្ថបទដោយ៖ មាស សុភាព



រូបភាពទី៨ ទង់ក្រពើពីរសម្រាប់អ្នកស្លាប់តែម្នាក់ (រូបថត: Entertainment And Knowledge)



រូបភាពទី៩ ស្បែកក្រពើអាធន់ ចងក្ដាងជាទង់ (រូបថត: ម៉ៅ សេងយាន)

អត្ថបទដោយ៖ មាស សុភាព



រូបភាពទី៦ ទង់ក្រពើចងពីមុខ បដិមាព្រះពុទ្ធក្នុងព្រះវិហារ

## ឯកសារពិគ្រោះ


ញាណ គៀន, ម៉ម ផៃ

២០០២, *លំអានទំនៀមខ្មែរបូរាណ*, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ។

ជួន ណាត

១៩៦៧, *វចនានុក្រមខ្មែរ ភាគ១*, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ។

ម៉ៅ សេងយាន

២០០៧, *ជំនឿទាក់ទងនឹងទង់*, មហាវិទ្យាល័យបុរាណវិទ្យា, ភ្នំពេញ។


អត្ថបទដោយ៖ មាស សុភាព